**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៤៥ សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ /៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

ប្រការ១-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.លោកជំទាវ **អ៊ឹង កន្ថាផាវី** | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤.ឯកឧត្តម **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |



www.pheakdeylaw.com

| | | |
|---|---|---|
| ៥.ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦.ឯកឧត្តម **ហង់ ជួនណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧.លោកជំទាវ **ឌូ ប៊ុនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៨.ឯកឧត្តម នាយឧត្តមសេនីយ៍ | **នេត សាវឿន** អគ្គស្នងការ នគរបាលជាតិ | អនុប្រធាន |
| ៩.ឯកឧត្តម **ស៊ុ គិរិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០.ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១.លោកជំទាវ **ជាំ ជារីនី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១២.ឯកឧត្តម **ឌូ ទិដ្ឋិ** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣.លោកជំទាវ **វ៉ែន សុមនា** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤.ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥.លោកជំទាវ **ម៉ាត់ ម៉ាត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦.លោកជំទាវ **ចាន់ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧.លោកជំទាវ **ឆូច សារ៉ុម** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៨.លោកជំទាវ **អ៊ាន់ ម៉ារា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៩.លោកជំទាវ **តាន់ ខ្ចឆេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០.លោកជំទាវ **ប្រាក់ ច័ន្ទណាយ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១.លោកជំទាវ **ហោ ម៉ាលីន** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២២.លោកជំទាវ **ឡាយ ណាទីន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៣.ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤.ឯកឧត្តម នាយឧត្តមសេនីយ៍ | **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៥.ឯកឧត្តម នាយឧត្តមសេនីយ៍ | **ម៉ៅ ច័ន្ទតារា** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦.ឯកឧត្តម នាយឧត្តមសេនីយ៍ | **សុខ ផល** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សៀក សុជាតិ** នាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |



www.pheakdeylaw.com

ប្រការ២-

ក្នុងករណីដែលក្រសួងស្ថាប័ន ឬអង្គភាពណាមួយមានការផ្លាស់ប្តូរសមាសភាពខាងលើ ត្រូវធ្វើសំណើមកប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីតែងតាំងជាថ្មី។

ប្រការ៣-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អង្គភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ១
-រាជកិច្ច
-ឯកសារ
-កាលប្បវត្តិ



www.pheakdeylaw.com